ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 19-Nov-2015, 15:17
CMS/CFO: Sann Rada

**អង្គជំនុំជម្រះតុលាការកំពូល**
Supreme Court Chamber
Chambre de la Cour supreme

សំណុំរឿងលេខ: ០០២/១៩-កញ្ញា-២០០៧/អ.វ.ត.ក/អ.ជ.ត.ក
Case File/Dossier N°. 002/19-09-2007/ECCC/SC

**នៅចំពោះមុខ៖**

**ចៅក្រម គង់ ស្រ៊ីម ប្រធាន**
**ចៅក្រម Chandra Nihal JAYASINGHE**
**ចៅក្រម សោម សិរីវឌ្ឍ**
**ចៅក្រម Agniezska KLONOWIECKAMILART**
**ចៅក្រម ម៉ុង មុនីចរិយា**
**ចៅក្រម Florence Ndepele Mwachande MUMBA**
**ចៅក្រម យ៉ា ណារិន**

| | |
|---|---|
| **កាលបរិច្ឆេទឯកសារ៖** | **ថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០១៥** |
| **ភាសាដើម៖** | **ខ្មែរ/អង់គ្លេស** |
| **ចំណាត់ថ្នាក់ឯកសារ៖** | **សាធារណៈ** |

# សេចក្តីសម្រេចបង្គាប់ឱ្យមេធាវី VICTOR KOPPE ដាក់សារណាទាក់ទងនឹង ការខកខានរបស់ខ្លួនក្នុងការចូលរួមសវនាការបណ្តឹងសាទុក្ខ

**<u>សហព្រះរាជអាជ្ញា</u>**

**<u>សហមេធាវីជនជាប់ចោទ នួន ជា</u>**

01173140



ជា លាង

Nicholas KOUMJIAN

**<u>ជនជាប់ចោទ</u>**

ខៀវ សំផន

នួន ជា

**<u>សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី</u>**

ពេជ អង្គ

Marie GUIRAUD

សុន អរុណ

Victor KOPPE

**<u>សហមេធាវីជនជាប់ចោទ ខៀវ សំផន</u>**

គង់ សំអុន

Anta GUISSÉ
Arthur VERCKEN

**អង្គជំនុំជម្រះតុលាការកំពូល**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យនៅចន្លោះពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩ ("**អង្គជំនុំជម្រះតុលាការកំពូល**" និង"**អ.វ.ត.ក**"),

**កត់សម្គាល់**សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០១ ប្រឆាំងនឹង នួន ជា និង ខៀវ សំផន ("សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង") ដែលបានចេញនៅថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៤[1],

**បានទទួល**បណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបានធ្វើឡើងដោយ សហព្រះរាជអាជ្ញា នួន ជា និង ខៀវ សំផន[2],

**កត់សម្គាល់**មាត្រា ៣០១ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ដែលតម្រូវដាច់ខាតថា ជនជាប់ចោទ ត្រូវតែ ទទួលបានជំនួយពីមេធាវី នៅពេលសវនាការ*ក្នុងចំណោមនោះ*មានដូចជាក្នុងករណីបទឧក្រិដ្ឋ និងវិធាន ៨១(៧) នៃវិធានផ្ទៃក្នុង ដែលចែងថា "នៅពេលមេធាវីរបស់ជនជាប់ចោទ មិនមានវត្តមានក្នុងអំឡុងពេល សវនាការដោយគ្មានការបញ្ជាក់អំពីមូលហេតុ អង្គជំនុំជម្រះ អាចពន្យារពេលសវនាការ ឬបើសិនជាជន ជាប់ចោទស្នើសុំជំនួយមេធាវី អាចស្នើសុំឲ្យអង្គភាពគាំពារការការពារក្តី ចាត់តាំងជាបណ្តោះអាសន្នជូន ជនជាប់ចោទនោះនូវមេធាវី [...]",

**កត់សម្គាល់**មាត្រា ២២(៤) វិធានផ្ទៃក្នុងដែលចែងថា "នៅក្នុងការបំពេញការងាររបស់ខ្លួន មេធាវីត្រូវ គោរពតាមបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀង ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

---

[1] សាលក្រមក្នុងសំណុំរឿង ០០២/០១ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៤ ឯកសារលេខ E313។

[2] បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០១ ចុះថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១៤ ឯកសារលេខ F11។ បណ្តឹងសាទុក្ខរបស់ នួន ជា ប្រឆាំងនឹងសាលក្រមក្នុងសំណុំរឿង ០០២/០១ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារលេខ F16។ *[កែតម្រូវលើកទី ១] បណ្តឹសាទុក្ខរបស់មេធាវីការពារក្តី ខៀវ សំផន ប្រឆាំងនឹងសាលក្រមក្នុងសំណុំរឿង ០០២/០១* ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារលេខ F17 (សំណៅត្រូវបានកែតម្រូវ ដែលបានដាក់នៅថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៤)។ *សូមមើលផងដែរ* សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា ប្រឆាំងនឹងសេចក្តីសម្រេច ថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៤ ឯកសារលេខ E313/3/1។ សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ ប្រឆាំងនឹងសាលក្រមក្នុងសំណុំរឿង ០០២/០១ ថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៤ ឯកសារលេខ E313/1/1។ សេចក្តីជូនដំណឹង អំពីបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី ខៀវ សំផន ប្រឆាំងនឹងសាលក្រមក្នុងសំណុំរឿង ០០២/០១ ថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៤ ឯកសារលេខ E313/2/1។

វិធានផ្ទៃក្នុង សេចក្ដីណែនាំអនុវត្ត និងបទបញ្ជារដ្ឋបាលរបស់អង្គជំនុំជម្រះវិសាមញ្ញ ក៏ដូចជាច្បាប់ស្ដីពីលក្ខន្តិកៈមេធាវីរបស់កម្ពុជា និង បទដ្ឋាន និង ក្រមសីលធម៌វិជ្ជាជីវៈ ដែលបានទទួលស្គាល់។ ពួកគេមានកាតព្វកិច្ចក្នុងការលើកកម្ពស់យុត្តិធម៌ និងដំណើរការនីតិវិធីប្រកបដោយប្រសិទ្ធិភាព និងត្រឹមត្រូវ"។

**កត់សម្គាល់**ផ្នែក ៧(១) នៃបទបញ្ជារដ្ឋបាលរបស់អង្គភាពគាំពារការការពារក្ដី ដែលចែងថា "យោងតាមបទបញ្ជារបស់ អ.វ.ត.ក សហមេធាវី ត្រូវកាន់រឿងក្ដីរហូតដល់ចប់។ ការខកខានធ្វើដូច្នោះ ដោយពុំមានមូលហេតុត្រឹមត្រូវដែលត្រូវបានយល់ព្រមដោយ អ.វ.ត.ក អាចបណ្ដាលឱ្យមានការបង់ប្រាក់ពិន័យទាំងមូល ឬផ្នែកខ្លះ ដូចបានកំណត់ដោយ អ.វ.ត.ក" និងផ្នែក ១៦(៥) នៃបទបញ្ជារដ្ឋបាលរបស់អង្គភាពគាំពារការការពារក្ដីដែលចែងថា "សហមេធាវី ត្រូវមានវត្តមាននៅ អ.វ.ត.ក នៅក្នុងករណីចាំបាច់ ដើម្បីការពារប្រកបដោយប្រសិទ្ធិភាពដល់ជនជាប់ចោទ និងនៅពេលណាដែលទទួលបានសេចក្ដីជូនដំណឹងដោយសមស្របឱ្យធ្វើដូច្នោះ [...]",

**រំលឹក**ថា ដីកាកំណត់កាលបរិច្ឆេទ[3] ដែលអង្គជំនុំជម្រះ *ក្នុងចំណោមនោះ* បានជូនដំណឹងភាគីថា សវនាការបណ្ដឹងសាទុក្ខសម្រាប់បណ្ដឹងសាទុក្ខខាងលើ នឹងត្រូវចាប់ផ្ដើមនៅថ្ងៃ អង្គារ ទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៥ វេលាម៉ោង ០៩:00 ព្រឹក នៅក្នុងបន្ទប់សវនាការធំរបស់ អ.វ.ត.ក ("សវនាការបណ្ដឹងសាទុក្ខ")[4],

**រំលឹក**ថា សហមេធាវីអន្តរជាតិការពារក្ដី នួន ជា លោក Victor KOPPE ពុំមានវត្តមាននៅពេលសវនាការបណ្ដឹងសាទុក្ខឡើយ,

**រំលឹក**ថា អង្គជំនុំជម្រះបានទទួលយកសំណើរបស់ នួន ជា ធ្វើការថ្លែងដោយផ្ទាល់ទៅកាន់អង្គជំនុំជម្រះនៅពេលចាប់ផ្ដើមសវនាការបណ្ដឹងសាទុក្ខ និងថា នៅក្នុងសេចក្ដីថ្លែងនោះ នួន ជា បានបញ្ជាក់*ក្នុងចំណោមនោះ*ថា ខ្លួន បានណែនាំសហមេធាវីអន្តរជាតិរបស់គាត់ មិនឱ្យមានវត្តមាន នៅពេលសវនាការ និងថា គាត់ នឹងណែនាំឱ្យសហមេធាវីជាតិលោក សុន អរុណ ចាកចេញពីបន្ទប់សវនាការ បន្ទាប់ពីគាត់បានថ្លែង,

**រំលឹក**ថា អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចនៅពេលសវនាការបណ្ដឹងសាទុក្ខថា សហមេធាវីជាតិការពារក្ដី នួន ជា ត្រូវតែមានវត្តមាននៅក្នុងបន្ទប់សវនាការដើម្បីធានាថា នួន ជា ត្រូវបានការពារដោយ

---

[3] ដីកាកំណត់កាលវិភាគស្ដាពរសម្រាប់សវនាការបណ្ដឹងសាទុក្ខ និងការជូនដំណឹងភាគីអំពីបញ្ហាដែលត្រូវដោះស្រាយ ថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ឯកសារលេខ F30/4 ("ដីកាកំណត់កាលបរិច្ឆេទ")។

[4] ដីកាកំណត់កាលបរិច្ឆេទ ទំព័រ ៥។

ត្រឹមត្រូវតាមច្បាប់នៅពេលសវនាការបណ្តឹងសាទុក្ខ ដូចបានកំណត់ក្នុងក្របខ័ណ្ឌផ្នែកច្បាប់ពាក់ព័ន្ធ បើទោះបីជា មេធាវីជាតិ ពុំមានបំណងធ្វើសារណាលើរឿងក្តី និងបើទោះបីជាផ្ទុយពីការណែនាំរបស់កូនក្តីខ្លួនក៏ដោយ,

**រំលឹក**ថា បើទោះបីជាការសម្រេចរបស់អង្គជំនុំជម្រះស្តីពីកាតព្វកិច្ចតម្រូវឱ្យមានវត្តមានក៏ដោយ ក៏សហមេធាវីជាតិការពារក្តី នួន ជា ពុំបានមានវត្តមាននៅក្នុងបន្ទប់សវនាការ នៅពេលដែលអង្គជំនុំជម្រះបន្តសវនាការបណ្តឹងសាទុក្ខបន្ទាប់ពីការសម្រាកនាព្រឹកនោះ,

**រំលឹក**ថា នៅថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០១៥ សហមេធាវីជាតិការពារក្តី នួន ជា បានដាក់ឯកសារបញ្ជាក់ពីជំហររបស់ខ្លួនទាក់ទងនឹងការខកខានចូលរួមផ្នែកខ្លះទៀតនៃសវនាការបណ្តឹងសាទុក្ខ[5],

**ពិចារណាឃើញ**ថា ការប្រព្រឹត្តរបស់សហមេធាវីការពារក្តី នួន ជា នឹងអាចនាំទៅដល់ការដាក់ទណ្ឌកម្មផ្នែកវិន័យ ឬផលវិបាកដទៃទៀត,

**ពិចារណាឃើញ**ថា មុនពេលអង្គជំនុំជម្រះតុលាការកំពូលចាត់វិធានការបន្ថែមទាក់ទងបញ្ហានេះ ជាការសមស្រប ក្នុងការផ្តល់ឱកាសបន្ថែមដល់សហមេធាវីអន្តរជាតិការពារក្តី នួន ជា ឱ្យពន្យល់ដោយខ្លួនឯងផ្ទាល់នូវមូលហេតុនៃការខកខានរបស់ខ្លួន ក្នុងការចូលរួមសវនាការបណ្តឹងសាទុក្ខ,

**អាស្រ័យហេតុនេះសម្រេចថា÷**

**បង្គាប់**ឱ្យសហមេធាវីអន្តរជាតិការពារក្តី នួន ជា ដាក់សារណាជាលាយលក្ខណ៍អក្សរយ៉ាងយូរត្រឹមថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ដោយពន្យល់នូវមូលហេតុនៃការខកខានរបស់ខ្លួនក្នុងការចូលរួមសវនាការបណ្តឹងសាទុក្ខ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០១៥

**ប្រធានអង្គជំនុំជម្រះតុលាការកំពូល**

E.C.C.C * C.E.T.C SUPREME COURT CHAMBER CHAMBRE DE LA COUR SUPRÊME

**គង់ ស្រ៊ឹម**

[5] ការឆ្លើយតបរបស់ សុន អរុណ ទៅនឹងសេចក្តីសម្រេចដោយផ្ទាល់មាត់របស់អង្គជំនុំជម្រះតុលាការកំពូលទាក់ទងនឹងព្រឹត្តិការណ៍នៅថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ឯកសារលេខ F30/13។